**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

# សេចក្តីប្រកាសព័ត៌មាន

អ្នកនាំពាក្យក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមេត្តាជ្រាបថា **ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៅតាមអគ្គនាយកដ្ឋាន និងអង្គភាពទាំងអស់ចំណុះឱ្យក្រសួងបរិស្ថាន និងគ្រប់មន្ទីរបរិស្ថានរាជធានី-ខេត្តទូទាំងប្រទេស** បានធ្វើការបដិសេធ និងថ្កោលទោស ចំពោះបុគ្គល និងបក្សពួក ដែលបានក្លែងបន្លំខ្លួនជាថ្នាក់ដឹកនាំក្រសួងបរិស្ថាន និងបានធ្វើការឃោសនាបង្កាច់បង្ខូចភូតកុហកនាំឱ្យប៉ះពាល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ថ្នាក់ដឹកនាំក្រសួងបរិស្ថាន។ ព័ត៌មានក្លែងបន្លំខាងលើនេះត្រូវបានផ្សាយបន្តដោយបណ្តាញសង្គមមួយចំនួនតូចផ្សេងទៀត ដែលមានចេតនាឃោសនាញុះញង់ សំដៅបង្កើតឱ្យមានអស្ថិរភាពក្នុងសង្គម បម្រើឱ្យក្រុមជ្រុលនិយម ដែលកំពុងអនុវត្តឧបាយកលដ៏ឧក្រិដ្ឋមកលើរាជរដ្ឋាភិបាលកម្ពុជារបស់យើងទៀតផង។

ពាក់ព័ន្ធនឹងការផ្សាយខាងលើ អ្នកនាំពាក្យក្រសួងបរិស្ថាន សូមបញ្ជាក់ជូនថា ថ្នាក់ដឹកនាំ និងមន្ត្រីក្រសួងបរិស្ថានទាំងអស់កំពុងសាមគ្គីគ្នា បំពេញការងារតាមតួនាទី ភារកិច្ច និងការទទួលខុសត្រូវខ្ពស់ក្នុងគោលបំណងតម្កល់នូវឧត្តមគតិដ៏ថ្លៃថ្លាចំពោះជាតិ និងមាតុភូមិកម្ពុជា ដោយជំរុញគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអនុវត្តយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឱ្យទទួលបានលទ្ធផលជោគជ័យជាច្រើនបន្តទៀត។

អ្នកនាំពាក្យក្រសួងបរិស្ថាន សូមធ្វើការបញ្ជាក់ជំហរយ៉ាងម៉ឺងម៉ាត់ដោយ «ប្រកាសថ្កោលទោស និងប្រឆាំងយ៉ាងដាច់អហង្ការចំពោះទង្វើទាំងឡាយរបស់បុគ្គល និងបក្សពួក ដែលបានផ្សព្វផ្សាយព័ត៌មានក្លែងបន្លំញុះញង់ ប្រឌិតព័ត៌មានភូតកុហក ធ្វើការបរិហារកេរ្តិ៍ បោកប្រាស់គ្រប់រូបភាពដល់មតិសាធារណៈ ដែលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ថ្នាក់ដឹកនាំក្រសួងបរិស្ថាន ក៏ដូចជាស្ថាប័នជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា»។

អ្នកនាំពាក្យក្រសួងបរិស្ថាន សូមស្នើដល់អាជ្ញាធរមានសមត្ថកិច្ចបន្តចាត់វិធានការឱ្យបានតឹងរឹងបំផុតតាមផ្លូវច្បាប់ចំពោះបុគ្គល និងបក្សពួកខាងលើ ដើម្បីថែរក្សា ការពារសុខសន្តិភាព និងការពារថ្នាក់ដឹកនាំ និងក្រសួងបរិស្ថានឱ្យបន្តបេសកកម្មដ៏ឧត្តុង្គឧត្តមក្នុងការបម្រើប្រជាពលរដ្ឋ និងប្រទេសជាតិ៕

ថ្ងៃអាទិត្យ ៨កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៤

អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ៖ ០២៣ ២១៣ ៩០៨ , ០២៣ ២២០ ៣៦៩ ទូរសារ៖ ០២៣ ២១២ ៥៤០